ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថាស្វាគមន៍
## លោកជំទាវបណ្ឌិត ជា សិរី អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីសម្ពោធអគារបណ្ណាល័យវិទ្យាល័យតាអោក
## ស្ថិតក្នុងឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ

ថ្ងៃសៅរ៍ ៩រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៥

សូមគោរព

- លោក Min Kyeongho អនុប្រធាននាយកប្រតិបត្តិ នៃធនាគារឯកទេស ខេប៊ី ដេហាន ម.ក
- លោក ឃឹម សុខឃាង អភិបាលនៃគណៈអភិបាលស្រុកប្រាសាទសំបូរ
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាគណៈអធិបតី
- លោកគ្រូ-អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និងបងប្អូនប្រជាពលរដ្ឋទាំងអស់ ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំមានកិត្តិយសនិងសេចក្ដីសោមនស្សរីករាយ ដែលបានចូលរួមក្នុងពិធីសម្ពោធអគារបណ្ណាល័យវិទ្យាល័យតាអោក ជាមួយ ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ-អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និងបងប្អូនប្រជាពលរដ្ឋ នៅឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ នាពេលនេះ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះការចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញមកចូលរួមក្នុងកម្មវិធីនារសៀលនេះ។

ឆ្លៀតក្នុងឱកាសដ៏មានតម្លៃនេះ ខ្ញុំសូមពាំនាំនូវការផ្ដាំផ្ញើសាកសួរសុខទុក្ខប្រកបដោយក្ដីនឹករឭកពីសំណាក់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលលោកតែងតែគិតគូរពីសុខទុក្ខរបស់ទាំងអស់នៅទូទាំងប្រទេស ជាពិសេសនៅខេត្តកំពង់ធំ។ វីរៈភាព និងស្នាដៃជាច្រើនរបស់ថ្នាក់ដឹកនាំទាំងអស់ដែលបានបន្សល់ទុកត្រូវបានអ្នកបន្តវេន ជំនាន់ក្រោយចងចាំ និងដឹងគុណជានិច្ច ចំពោះសមិទ្ធផលទាំងឡាយដែលជាមូលដ្ឋានដ៏រឹងមាំ នាំមកនូវការអភិវឌ្ឍរីកចម្រើន ជាពិសេស តាមរយៈគោលនយោបាយ ឈ្នះ ឈ្នះ របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានធ្វើឱ្យប្រទេសកម្ពុជាមានសុខសន្តិភាព មានការអភិវឌ្ឍ



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

លើគ្រប់វិស័យ និងមានកិត្តិនាមល្បីរន្ទឺទាំងក្នុងតំបន់ និងលើឆាកអន្តរជាតិ។ ក្នុងនោះវិស័យអប់រំក៏មានការរីកចម្រើន និងបានដើរតួនាទីស្នូល ក្នុងការកសាងធនធានមនុស្ស សម្រាប់រួមចំណែកអភិវឌ្ឍប្រទេសជាតិយ៉ាងសកម្មប្រកបដោយប្រសិទ្ធភាព។

ខ្ញុំសូមអបអរសាទរចំពោះអគារបណ្ណាល័យ ទំហំ១២ម៉ែត្រ គុណនឹង៩ម៉ែត្រ ដែលបានរចនាដោយគិតគូរ គ្រប់ជ្រុងជ្រោយអំពីផាសុកភាព ខ្យល់ចេញ-ចូល ពន្លឺគ្រប់គ្រាន់ ដែលនេះគឺជាសមិទ្ធផលថ្មីមួយបន្ថែមទៀតសម្រាប់វិទ្យាល័យតាអោក នាពេលនេះ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំ និងគណៈគ្រប់គ្រងនៃធនាគារឯកទេស ខេប៊ី ដេហាន ម.ក ដែលបានឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុ ក្នុងការកសាងអគារបណ្ណាល័យនេះឡើង ព្រមទាំងសូមថ្លែងអំណរគុណចំពោះអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ មន្ទីរអប់រំ យុវជន និងកីឡា លោកនាយក លោកគ្រូ-អ្នកគ្រូ និង ដៃគូអភិវឌ្ឍន៍នានា ដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អ និងរួមសាមគ្គីគ្នា ធ្វើឱ្យអគារបណ្ណាល័យនេះលេចរូបរាងឡើង ដើម្បីជាកន្លែងសម្រាប់សិស្សានុសិស្សទាំងអស់ អាចធ្វើការសិក្សាស្រាវជ្រាវ ស្វែងយល់នូវចំណេះដឹងនានា និងចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ចាប់យកជំនាញសមស្របសម្រាប់ប្រកបការងារចិញ្ចឹមជីវិតនាពេលអនាគត។ លើសពីនេះសមិទ្ធផលថ្មីនេះនឹងផ្តល់ឱកាសដល់សិស្សានុសិស្សទាំងអស់ មិនត្រឹមតែនៅក្នុងវិទ្យាល័យតាអោកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសិស្សានុសិស្ស ដែលមកពីសាលាផ្សេងៗនៅក្នុងឃុំឈូក ដើម្បីធ្វើការស្រាវជ្រាវ និងសិក្សាស្វែងយល់បន្ថែមទៀត។ គិតមកដល់ពេលបច្ចុប្បន្ននេះ នៅក្នុងឃុំឈូកទាំងមូល គឺមានសាលាសរុបចំនួន ១៨ បែងចែកជា មត្តេយសិក្សា (៧) បឋមសិក្សា (៨) អនុវិទ្យាល័យ (២) និងវិទ្យាល័យ (១) ដោយមានសិស្សានុសិស្សសរុបចំនួន ២.៩៣៦នាក់ (ស្រី ១.៤៦៤នាក់) លោកគ្រូ ៥៦នាក់ និងអ្នកគ្រូ ៦៨នាក់។

ដោយឡែកនៅសាលាតាអោក គឺមានសិស្សានុសិស្សសរុប ចំនួន ១.៣៧៣នាក់ (ស្រី ៧៣១នាក់) ស្មើប្រមាណ ៤៧% នៃចំនួនសិស្សានុសិស្សសរុបក្នុងឃុំឈូកទាំងមូល ក្នុងនោះសាលាមត្តេយ្យ និងបឋមសិក្សា មានចំនួន ៥១៧នាក់ (ស្រី ២៥២នាក់) វិទ្យាល័យសិក្សាមានចំនួន ៨៥៦នាក់ (ស្រី ៤៧៩នាក់)។

## ក្មួយៗសិស្សានុសិស្សទាំងអស់ ដឹងទេ តើបណ្ណាល័យគឺជាអ្វី?

បណ្ណាល័យ គឺជាឃ្លាំងតម្កល់ ឬបណ្តុំនៃប្រភពព័ត៌មាន ឯកសារ និងធនធាន ដែលយើងទាំងអស់គ្នាអាចចូលទៅអាន ឬខ្ចីអាន ឬសិក្សាស្រាវជ្រាវឯកសារអ្វីមួយ ហើយឯកសារទាំងនោះអាចជាសៀវភៅ (ដែលយើងហៅថា Hardcopy ជាភាសាអង់គ្លេស)។

បណ្ណាល័យមានសារៈសំខាន់ណាស់ក្នុងការលើកកម្ពស់គុណភាពអប់រំ ការសិក្សាស្រាវជ្រាវ

របស់សិស្ស ការបណ្ដុះទម្លាប់អាននិងវប្បធម៌សិក្សាពេញមួយជីវិតដល់សិស្សនិងសហគមន៍ទូទៅ និងគាំទ្រដល់ការបង្រៀនរបស់លោកគ្រូ-អ្នកគ្រូ នៅតាមសាលារៀនផងដែរ។ ដូច្នេះហើយ បានជាក្រសួងអប់រំ យុវជន និងកីឡា បោះពុម្ពសៀវភៅឯកសារជាច្រើនសម្រាប់គាំទ្រដល់គ្រឹះស្ថានសិក្សានានា។ ទោះបីជាភាពរីកចម្រើននៃបច្ចេកវិទ្យាធ្វើឱ្យសិស្សនិស្សិតនាពេលបច្ចុប្បន្ននេះអាចស្វ័យសិក្សា និងអានឯកសារតាមរយៈប្រព័ន្ធអេឡិចត្រូនិច ប៉ុន្តែនៅតែមានសិស្ស-និស្សិតនិយមចូលចិត្ត ឬបន្តជ្រើសរើសទៅសិក្សាស្រាវជ្រាវ និងអានសៀវភៅនៅទីតាំងបណ្ណាល័យផ្ទាល់។ នាពេលបច្ចុប្បន្ននេះ ក្នុងបណ្ណាល័យ មិនត្រឹមតែមានតែសៀវភៅបោះពុម្ពដាក់តាំងនៅលើធ្នើរប៉ុណ្ណោះទេ ប៉ុន្តែបណ្ណាល័យថែមទាំងបានផ្ដល់នូវភាពសម្បូរបែបជាច្រើនទៀត ដូចជាបណ្ដាញតភ្ជាប់ទៅកាន់គេហទំព័រទាញយកសៀវភៅមួយចំនួនទៀត ដែលពុំមាន ឬពុំទាន់បោះពុម្ព។ លើសពីនេះ បណ្ណាល័យមានការផ្ដល់ជូននូវសេវាកម្មឥតគិតថ្លៃនានាតាមរយៈបណ្ណារក្ខដែលប្រចាំការនៅទីតាំងបណ្ណាល័យនីមួយៗដោយផ្ទាល់។

សរុបមក មីងសង្ឃឹមថា ក្មួយៗសិស្សានុសិស្សទាំងអស់ ពិតជាបានយល់ និងស្រឡាញ់ចូលចិត្តការអាន ព្រោះការអាននិងស្វ័យសិក្សាបន្ថែមទៀត ទើបធ្វើឱ្យក្មួយៗអាចទទួលបាននូវចំណេះដឹងថ្មីៗ និងអភិវឌ្ឍខ្លួនកាន់តែរីកចម្រើនទៅពេលអនាគត។

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅម្ដងទៀតចំពោះថ្នាក់ដឹកនាំ និងគណៈគ្រប់គ្រងនៃធនាគារឯកទេស ខេប៊ី ដេហាន ម.ក ដែលបានផ្ដួចផ្ដើមក្នុងការកសាងអគារបណ្ណាល័យវិទ្យាល័យតាអោក នេះឡើង។ ខ្ញុំសូមអំពាវនាវឱ្យលោកគ្រូ-អ្នកគ្រូ សិស្សានុសិស្សទាំងអស់ សូមជួយថែរក្សាអគារបណ្ណាល័យនេះឱ្យបានគង់វង្សជាប្រយោជន៍ ដើម្បីប្រើប្រាស់សមិទ្ធផលទាំងនេះឱ្យបានយូរអង្វែង។ ជាងនេះទៀត ការថែរក្សាទ្រព្យសម្បត្តិដែលមានឱ្យបានគង់វង្ស នឹងបន្តជំរុញលើកទឹកចិត្តដល់ម្ចាស់ជំនួយ បន្តជួយយើង តាមរយៈការសាងសង់អគារបណ្ណាល័យ បន្ថែមទៀតនៅតាមវិទ្យាល័យ អនុវិទ្យាល័យ និងសាលាបឋមសិក្សា នាពេលអនាគត។

ជាថ្មីម្ដងទៀត ថ្ងៃនេះខ្ញុំ តំណាងធនាគារជាតិនៃកម្ពុជា ក៏បាននាំយកនូវអំណោយ និងប្រាក់ឧបត្ថម្ភ ដើម្បីចែកជូនបងប្អូនប្រជាពលរដ្ឋយើងសរុបប្រមាណ ៥០០នាក់ ដែលក្នុងនោះរួមមាន៖

១/- ប្រាក់ឧបត្ថម្ភរៀបចំកម្មវិធី ចំនួន ២.០០០.០០០រៀល

២/- ឧបត្ថម្ភជូនមន្ត្រីរាជការ ចំនួន៥០នាក់ ក្នុងម្នាក់ទទួលបានសារុង១ និងថវិកា ៣០.០០០ រៀល

៣/- ឧបត្ថម្ភជូន នាយក នាយករង លោកគ្រូ និងអ្នកគ្រូ ចំនួន៥០នាក់ ក្នុងម្នាក់ទទួលបាន សារុង១ និងថវិកា ៣០.០០០រៀល

៤/- ឧបត្ថម្ភជូន សិស្សានុសិស្ស (ថ្នាក់ទី១១-១២) ចំនួន២០០នាក់ ក្នុងម្នាក់ទទួលបាន

សៀវភៅ២ក្បាល ប៊ិក២ដើម ខ្មៅដៃ១ដើម និងថវិកា ២០.០០០រៀល និង

៥/- ឧបត្ថម្ភជូន តំណាងមាតាបិតា និងប្រជាពលរដ្ឋ ចំនួន១០០នាក់ ក្នុងម្នាក់ទទួលបាន សារុង១ និងថវិកា ២០.០០០រៀល។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ដែលជាគណៈអធិបតី ព្រមទាំង លោកគ្រូ-អ្នកគ្រូ មាតា បិតា ក្មួយៗសិស្សានុសិស្ស និងបងប្អូនប្រជាពលរដ្ឋទាំងអស់ សូមមានសុខភាពល្អ កម្លាំងមាំមួន និងសូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**